# ឯកសារសង្ខេបអំពីដៃគូអនុវត្តគម្រោង
# ផ្នែកពិការភាព

## សង្ខេបគម្រោង

កម្មវិធីអភិវឌ្ឍសហប្រជាជាតិ (យូអិនឌីភី) កំពុងធ្វើការ ក្នុងភាពជាដៃគូជាមួយនឹងក្រុមប្រឹក្សាសកម្មភាពជនពិការ ដោយបានសម្របសម្រួលជាមួយក្រសួងស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការតំណាងជនពិការ (DPOs) និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីចូលរួមចំណែកក្នុងការអនុវត្ត ផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព (NDSP2 ២០១៩-២០២៣) ។ គម្រោងនេះមានគោលបំណងពង្រឹងយន្តការសម្របសម្រួល និងកៀរគរធនធានដើម្បីអនុវត្ត NDSP2 ប្រកបដោយប្រសិទ្ធភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## លទ្ធផលរំពឹងទុករបស់គម្រោង

- ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) ផ្តល់ដំបូន្មាន សម្របសម្រួល និងត្រួតពិនិត្យការអនុវត្ត NDSP2 ប្រកបដោយប្រសិទ្ធភាព។
- កម្មវិធីវិនិយោគឃុំ/សង្កាត់ (CIP) ដែលដំណើរការនៃថវិកា និងការអភិវឌ្ឍរបស់វា មានបរិយាបន្នពិការភាព តាមរយៈការចូលរួមយ៉ាងសកម្មរបស់ អង្គការជនពិការ (DPOs)/ អង្គការជនពិការកម្ពុជា (CDPO) និងយន្តការនានារបស់ក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់ខេត្ត។
- ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) ក្រុមការងារឆ្លើយតបពិការភាពខេត្ត (DAWGs) និងក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់ខេត្ត មានសមត្ថភាពក្នុងការអភិវឌ្ឍ និងអនុវត្តគោលនយោបាយ និងថវិកាប្រកបដោយបរិយាបន្នពិការភាព។

## កិច្ចអន្តរាគមន៍សំខាន់ៗ

- គាំទ្រដល់ការសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្ត NDSP 2
- គាំទ្រដល់ការធ្វើវិសោធនកម្មច្បាប់ពិការភាព និងអភិវឌ្ឍ / ពិនិត្យឡើងវិញ នូវក្របខ័ណ្ឌច្បាប់ជាតិទាក់ទងនឹងពិការភាព។
- គាំទ្រដល់អង្គការជនពិការ ដើម្បីចូលរួមក្នុងការអភិវឌ្ឍ កម្មវិធីវិនិយោគឃុំ/សង្កាត់ (CIP) និងផ្តល់ការបណ្តុះបណ្តាលអំពី ការអភិវឌ្ឍ CIP ប្រកបដោយបរិយាបន្នពិការភាព។

| |
|---|
| • ជំរុញ កម្មវិធី CIPs ដែលប្រកបដោយបរិយាបន្នពិការភាព នៅក្នុងឃុំដែលបានជ្រើសរើស និងរៀបចំប្រមូលមេរៀនផ្សេងៗដែលបានរៀន សម្រាប់ការយកមកអនុវត្តឡើងវិញ។<br>• កសាងសមត្ថភាព DAC, DAWG និង DAC ថ្នាក់ខេត្ត ក្នុងការដាក់បញ្ចូលពិការភាព ក៏ដូចជាការធ្វើផែនការ និងរៀបចំថវិកា។ |
| **កិច្ចអន្តរាគមន៍ជាពិសេស ចំពោះការទប់ស្កាត់ការរីករាលមេរោគ កូវីដ-១៩** |
| • ផលិតវីឌីអូចំនួន ៥ ដើម្បីបង្កើនការយល់ដឹងពាក់ព័ន្ធនឹងកូវីដ-១៩ ជាពិសេសក្នុងបរិបទជនមានពិការភាព។ វីឌីអូទាំងនេះ កំពុងត្រូវបានផលិត និងគ្រោងនឹងផ្សព្វផ្សាយដល់សាធារណៈជននៅពាក់កណ្តាលខែ មិថុនា ឆ្នាំ ២០២០។ វិឌីអូទាំងនេះ ក៏នឹងត្រូវបានចែករំលែក និងផ្សព្វផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយនានា ដូចជាប្រព័ន្ធផ្សព្វផ្សាយសង្គម និងស្ថានីយ៍ទូរទស្សន៍ក្នុងស្រុក។ |
| **ក្រុមគោលដៅ** |
| • ក្រុមគោលដៅផ្ទាល់៖ ប្រជាជនគ្រប់រូបដែលមានពិការភាពក្នុងទម្រង់ផ្សេងៗ រាប់បញ្ចូលទាំងស្ត្រីដែលមានពិការភាព<br>• ក្រុមគោលដៅប្រយោល៖ គ្រួសាររបស់ជនមានពិការភាព សហគមន៍ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីរដ្ឋាភិបាល |
| **តំបន់គោលដៅ** |
| ខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តត្បូងឃ្មុំ |
| **ដៃគូអនុវត្តគម្រោង** |
| ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) អង្គការជនពិការកម្ពុជា (CDPO) អង្គការឡៃហ្វ៍រឺឌីវើល (LFTW) |
| **រយៈពេលអនុវត្តគម្រោង** |
| ខែមករា ឆ្នាំ ២០២០ ដល់ ខែមិថុនា ឆ្នាំ ២០២១ |
| **ថវិកាគម្រោង** |
| ថវិកាសរុប៖ ៦៩៤,៥១៥ ដុល្លារអូស្ត្រាលី (ថវិកាពី ACCESS៖ ៥២៥,០០០ ដុល្លារអូស្ត្រាលី) |
| **ព័ត៌មានទំនាក់ទំនង** |


| | |
|---|---|
| យូអិនឌីភី (UNDP) | កម្មវិធី ACCESS |
| លោកស្រី **មាស ម៉ៅ** | លោក **ជូ វិវឌ្ឍន៍** |
| មន្ត្រីកម្មវិធី | ប្រធានផ្នែកពិការភាព |
| ទូរស័ព្ទ៖ (៨៥៥) ១៦ /១២ ៩១០ ០០៦ | ទូរស័ព្ទ៖ (៨៥៥) ១២ ៩១៥ ៦៧៤ |
| អ៊ីម៉ែល៖ mao.meas@undp.org | អ៊ីម៉ែល៖ vivath.ch@accesscambodia.org |

Sustainable quality services for all

គម្រោងនេះឧបត្ថម្ភដោយរដ្ឋាភិបាលអូស្រ្តាលី តាមរយៈកម្មវិធី សហប្រតិបត្តិការអូស្រ្តាលី-កម្ពុជា ដើម្បីសេវាប្រកបដោយនិរន្តរភាព និងសមធម៌ (ACCESS)។

ខែឧសភា ឆ្នាំ២០២០